**Declassified to Public**
**25 January 2019**

**គណៈមេធាវីទីក្រុងអាំស្ទែដាំ**

**សម្ងាត់**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)
ផ្ញើជូនលោក K. Roberts មន្ត្រីច្បាប់ជាន់ខ្ពស់
ប្រអប់សំបុត្រ ៧១
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ទីក្រុងអាំស្ទែដាំ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៨
PvRA/kb

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Mar-2018, 14:18
CMS/CFO: Sann Rada

**យោងរបស់យើង៖** **40-15-0862**
**យោងរបស់លោក៖ លោក នួន ជា សំណុំរឿង ០០២/០២**

លោក Roberts ជាទីរាប់អាន!

ខ្ញុំសូមភ្ជាប់ជូននូវសំណៅមួយច្បាប់នៃលិខិតរបស់ខ្ញុំនៅថ្ងៃនេះដែលបានផ្ញើជូនក្រុមប្រឹក្សាវិន័យ (ឯកសារភ្ជាប់ជាមួយ) និងសំណៅមួយច្បាប់នៃបញ្ជីឈ្មោះឯកសារភ្ជាប់ជាមួយ (ឯកសារភ្ជាប់ជាមួយ)។

ក្រុមប្រឹក្សាវិន័យ នឹងបន្តជូនដំណឹងលោកអំពីការវិវត្តនានាក្នុងពេលវេលាសមស្រប។

សូមលោកទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

[ហត្ថលេខា]
P.N. Van Regteren Altena

ប្រធានគណៈមេធាវីទីក្រុង AMSTERDAM
លោក P.N. Van Regteren Altena

Paulus Potterstraat 18 • Tel. (020) 589 60 39 • Fax (020) 589 60 30 • ADDRESS FOR CORRESPONDENCE:
PO BOX 57590, 1040 BL AMSTERDAM
www.advocatenorde-amsterdam.nl


Note: This Khmer translation is based on the English version which was translated from the original Dutch text.

**គណៈមេធាវីទីក្រុងអាំស្ទែដាំ**

**សម្ងាត់**
ក្រុមប្រឹក្សាវិន័យ
ផ្ញើជូនលោកស្រី S. van Excel មន្ត្រីរដ្ឋបាល
Postbus 76334
1070 EH អាំស្ទែដាំ

ទីក្រុងអាំស្ទែដាំ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៨
PvRA/kb

**យោង៖ អង្គជំនុំជម្រះសាលាដំបូង ប្រទេសកម្ពុជា/លោក** V. Koppe
**សំណុំរឿង៖ 40-15-0862**

លោកស្រី ជាទីរាប់អាន!

ខ្ញុំសូមជម្រាបជូនលោកស្រីអំពីបណ្ដឹងរបស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (បន្ទាប់ពីនេះទៅហៅថា អ.វ.ត.ក) ប្រឆាំងនឹងលោក V.L. Koppe ដែលបណ្ដឹងមួយចំនួនពាក់ព័ន្ធទៅនឹងរយៈកាលរហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ ដែលលោក Koppe នៅមានឈ្មោះក្នុងបញ្ជីជាមេធាវីក្នុងទីក្រុងអាំស្ទែដាំ ប៉ុន្តែតាមពិត គាត់មានការិយាល័យមេធាវីក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជាជាច្រើនឆ្នាំមកហើយ ហើយបណ្ដឹងមួយចំនួនទៀតពាក់ព័ន្ធទៅនឹងរយៈកាលដែលលោក Koppe នៅមានឈ្មោះជាមេធាវីក្នុងប្រទេសកម្ពុជា ប៉ុន្តែមិនមានឈ្មោះជាមេធាវីនៅក្នុងប្រទេសហូឡង់ទេ។ ហេតុនេះអនុលោមតាមបទដ្ឋានប្រទេសហូឡង់ គាត់គឺជាអតីតមេធាវីហូឡង់។

អាសយដ្ឋានមានដូចខាងក្រោមនេះ៖

<u>ដើមបណ្ដឹង៖</u>

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”)
ផ្ញើជូនលោក K. Roberts
ប្រអប់សំបុត្រលេខ ៧១
រាជធានីភ្នំពេញ


Note: This Khmer translation is based on the English version which was translated from the original Dutch text.

ព្រះរាជាណាចក្រកម្ពុជា
(roberts13@un.org)

**ចុងចម្លើយ៖**
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")
ក្រុមមេធាវីការពារក្តី នួន ជា
ផ្ញើជូនលោក V.L. Koppe
ប្រអប់សំបុត្រលេខ ៧១
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
(koppe@un.org)

ប្រធានគណៈមេធាវីទីក្រុង AMSTERDAM
លោក P.N. Van Regteren Altena

Paulus Potterstraat 18 • Tel. (020) 589 60 39 • Fax (020) 589 60 30 • ADDRESS FOR CORRESPONDENCE:
PO BOX 57590, 1040 BL AMSTERDAM
www.advocatenorde-amsterdam.nl

## ១. បណ្តឹង

ចុងចម្លើយ កំពុងប្រកបវិជ្ជាជីវៈនៅ អ.វ.ត.ក ក្នុងនាមជាមេធាវីរបស់លោក នួន ជា ដែលជាជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យកំពុងទទួលការជំនុំជម្រះក្តីពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហមដែលដឹកនាំដោយប៉ុល ពត) រវាងថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។ ចុងចម្លើយ បានជួយការពារក្តី នួន ជា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង រួមគ្នាជាមួយនឹងសហការីរបស់គាត់ឈ្មោះ M. Pestman ហើយក្រោយមក គាត់ជាមេធាវីជនជាតិហូឡង់តែម្នាក់គត់ទាំងនៅអង្គជំនុំជម្រះសាលាដំបូង ទាំងនៅអង្គជំនុំជម្រះតុលាការកំពូល។ លោក Koppe បានតំណាងឲ្យនួន ជា អស់រយៈពេលជាច្រើនឆ្នាំមកហើយ ហើយក៏មានទីលំនៅនៅក្នុងប្រទេសកម្ពុជា ផងដែរ ដោយសារការងារនេះ។

ក្នុងនាមជាមេធាវីតំណាងឲ្យជនសង្ស័យ លោក Koppe ត្រូវគោរពតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលមានចែងដូចជា៖ ប្រសិនបើមេធាវីបំពេញកិច្ចដោយរំលោភបំពានលើវិធានរបស់ អ.វ.ត.ក សមត្ថកិច្ចគ្រប់គ្រងនៅក្នុងប្រទេសដែលមេធាវីនោះប្រកបវិជ្ជាជីវៈ មានសិទ្ធិដោះស្រាយបណ្តឹងនេះ ស្របតាមបញ្ញត្តិជាធរមាននៅក្នុងប្រទេសនោះ។

ហើយច្បាស់ផងដែរគឺថា ខ្ញុំមានសមត្ថកិច្ចក្នុងនាមជាប្រធានគណៈមេធាវី ក្នុងការស៊ើបអង្កេតលើបណ្តឹងដែល អ.វ.ត.ក បានដាក់មក ហើយក្រុមប្រឹក្សារបស់លោកស្រី ក៏មានសមត្ថកិច្ចសម្រេចលើបញ្ហានេះក្នុងនាមជាចៅក្រមវិន័យ។

ដើមបណ្តឹង បានប្តឹងដោយសង្ខេបៗថា ចុងចម្លើយ មានកំហុសប្រព្រឹត្តខុសមកលើចៅក្រមនៅ អ.វ.ត.ក ហើយចុងចម្លើយក៏បានចែកចាយសេចក្តីថ្លែងការណ៍នានាទៅប្រព័ន្ធផ្សព្វផ្សាយ ដែលទង្វើបែបនេះគឺជាការប្រព្រឹត្តិខុសបើតាមការយល់ឃើញរបស់ដើមបណ្តឹង ហើយជាងនេះទៀត ចុងចម្លើយ បានចែកចាយទៅប្រព័ន្ធផ្សព្វផ្សាយដោយរំលោភបំពានលើដីកាបង្គាប់ឲ្យរក្សាការសម្ងាត់ចំពោះ“សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សា”របស់គាត់។

ចុងចម្លើយ គឺជាមេធាវីរបស់ជនសង្ស័យម្នាក់នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ បណ្តឹងបានធ្វើឡើងដំបូងនៅអង្គជំនុំជម្រះសាលាដំបូង ដែលជនសង្ស័យកំពុងទទួលការជំនុំជម្រះក្តី។

## ២. ការស៊ើបអង្កេត

២.១. ដំណើរការស៊ើបអង្កេត មានពន្យល់នៅក្នុងសំណុំរឿងភ្ជាប់មកជាមួយ។

២.២. ខ្លួនខ្ញុំផ្ទាល់បានធ្វើការស៊ើបអង្កេតនេះ។

២.៣. មិនមាននីតិវិធីសម្របសម្រួលទេ។



Note: This Khmer translation is based on the English version which was translated from the original Dutch text.

២.៤. ដើមបណ្តឹងបានបង់ថ្លៃរដ្ឋបាលតុលាការរួចហើយ។

## ៣. ខ្លឹមសារនៃបណ្តឹង (ឧបសម្ព័ន្ធ ១, ៩ និង ១៦)

នៅក្នុងលិខិតបណ្តឹងចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ អ.វ.ត.ក បានចោទចុងចម្លើយ ពីបទប្រព្រឹត្តខុសនៅក្នុងសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង(ខាងអន្តរជាតិ)ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ (ឧបសម្ព័ន្ធ ១) ដោយចុងចម្លើយ បានធ្វើសេចក្តីថ្លែងការណ៍ដូចខាងក្រោមនេះនៅក្នុងអំឡុងពេលសវនាការ ហើយក្រោយមក បានដើរចេញពីសាលសវនាការ។

- ចុងចម្លើយ ធ្លាប់បានធ្វើសេចក្តីអះអាងមួយនៅពេលដែលការពារក្តីរបស់គាត់ ដោយបាននិយាយថា ចៅក្រម Lavergne ដែលជាចៅក្រមម្នាក់ក្នុងចំណោមចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង "បានធ្វើសេចក្តីសម្រេចយ៉ាងកំសាក ហើយខ្វះសុចរិតភាពតុលាការម្តងហើយម្តងទៀត"។
- ចុងចម្លើយ បានជម្រាបចៅក្រម Fenz ថា គាត់សោកស្តាយ"យ៉ាងខ្លាំងណាស់"ដែលក្រុមការងាររបស់គាត់បានធ្វើសេចក្តីសម្រេចដោយមិនទាមទារប្តឹងជំទាស់ចិត្តប្រឆាំងចៅក្រម Lavergne ហើយចុងចម្លើយបានបង្ហាញថា បើប្រៀបធៀបបទពិសោធន៍របស់គាត់ជាមួយនឹងការជំនុំជម្រះក្តីផ្សេងទៀត "ចៅក្រម Cartwright ពិតជាពន្លឺដ៏ចាំងចែង និងត្រចះត្រចង់នៃភាពឥតលម្អៀង"។
- ចុងចម្លើយ បានបញ្ជាក់ថែមទៀតថា "ជាការពិតណាស់ដែលថា ជាឯកសិទ្ធិរបស់ចៅក្រម មិនឱ្យខ្ញុំនិយាយ។ ហើយជាឯកសិទ្ធិរបស់ខ្ញុំដែលមិននិយាយថែមទៀតទេ។ ដូច្នេះ គឺថា ទទួលយក ឬទុកចោល។ ឬគ្មានអ្វីទេ"។
- ចុងចម្លើយ បានថ្លែងទៅកាន់ចៅក្រម Lavergne ថា "ខ្ញុំកំពុងតែជម្រាបជូនលោកចៅក្រម អំពីមូលហេតុរបស់ខ្ញុំ ប៉ុន្តែ លោកចៅក្រម មិនចង់ស្តាប់ខ្ញុំទេ"។
- ចុងចម្លើយ បានជម្រាបចៅក្រម Lavergne ថា "លោកចៅក្រម Lavergne និយាយដោយស្មោះត្រង់ទៅ ខ្ញុំពិតជាមិនខ្វល់ពីអ្វីដែលលោកចៅក្រមគិតនោះទេ"។
- ចុងចម្លើយ ក៏បានកត់សម្គាល់ថា ប្រសិនបើ អ.វ.ត.ក គឺជាតុលាការប្រើច្បាប់កុំមិនឡូ វិញ ហើយ "ប្រសិនបើខ្ញុំត្រូវចោទពីបទមើលងាយតុលាការនោះ ខ្ញុំសប្បាយនឹងនឹងសារភាព។ ពិតណាស់ ខ្ញុំមិនមានអ្វីទេ ក្រៅពីមើលងាយខាងវិជ្ជាជីវៈលើចៅក្រមអន្តរជាតិ នៅក្នុងការជំនុំជម្រះក្តីនេះ"។



Note: This Khmer translation is based on the English version which was translated from the original Dutch text.

នៅក្នុងសេចក្ដីបន្ថែមចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ (ឧបសម្ព័ន្ធ ៩) អ.វ.ត.ក បានពង្រីកបណ្ដឹងហើយបានជំទាស់នឹងយោបល់មួយចំនួនដែលចុងចម្លើយ បានលើកឡើងនៅក្នុងបទសម្ភាសន៍មួយជាមួយនឹងសារព័ត៌មាន Mekong Review ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦។ សេចក្ដីបន្ថែមនេះពាក់ព័ន្ធនឹងយោបល់ដូចខាងក្រោម៖

- នៅពេលដែលគេសួរថាតើចុងចម្លើយនឹងផ្លាស់ប្ដូរទង្វើរបស់ខ្លួនដែរឬអត់ គាត់បានឆ្លើយថា "ទេ។ ខ្ញុំមានការមើលងាយយ៉ាងខ្លាំងខាងវិជ្ជាជីវៈលើចៅក្រមបារាំង (Jean-Marc Lavergne)" ជាពិសេស។ ប្រសិនបើជ្រុលពេក ឲ្យទៅចឹងចុះ"។
- នៅពេលដែលគេសួរថាតើចុងចម្លើយមានអ្វីជំទាស់នឹងចៅក្រមខាងលើដែរឬអត់ គាត់ឆ្លើយថា "បាទមាន"។ អ្នកសម្ភាសន៍ឈ្មោះ Mingh Bui Jones បានសួរថា "តើនេះដោយសារតែគាត់ជាជនជាតិបារាំងឬ?"។ ចុងចម្លើយបានឆ្លើយថា "ទេ មិនមែនដោយសារគាត់ជាជនជាតិបារាំងទេ មិនមែនទេ ខ្ញុំចូលចិត្តជនជាតិបារាំង។ ងាយពេកហើយ។ គាត់ធ្វើគ្រប់យ៉ាងដែលគាត់អាចធ្វើបានដើម្បីរារាំងខ្ញុំមិនឲ្យសួរសំណួរ។ គាត់កំពុងដើរលើផ្លូវដើម្បីព្យាយាម និងរារាំងខ្ញុំកុំឲ្យនិយាយរឿង[របស់ខ្លួន ជា]"។
- "ពាក្យថា៖ ពិតណាស់ ខ្ញុំមិនមានអ្វីទេ ក្រៅពីមើលងាយខាងវិជ្ជាជីវៈលើចៅក្រមអន្តរជាតិ" គឺជាប្រយោគដែលខ្ញុំបានគិតចេញរួចហើយមុននឹងខ្ញុំនិយាយចេញ"។ តាមបទសម្ភាសន៍នេះ នៅពេលដែលគេសួរថាតើចុងចម្លើយគិតថានឹងមានប្រតិកម្មតបដែរឬអត់ គាត់និយាយថា "បាទ ខ្ញុំបានជ្រើសរើសពាក្យទាំងនោះយ៉ាងប្រយ័ត្នប្រយែង។ ខ្ញុំបានជ្រើសរើសពាក្យទាំងនោះ ពីព្រោះថា ពាក្យទាំងនោះនៅពេលនោះនៅចុងមាត់ខ្ញុំអាចនិយាយចេញ ហើយឥឡូវនេះនៅតែនៅចុងមាត់ខ្ញុំអាចនិយាយចេញ"។
- "ប្រសិនបើលោកនៅក្នុងសាលសវនាការនោះមួយថ្ងៃចូល មួយថ្ងៃចេញ លោកដឹងហើយ... មួយថ្ងៃចូល មួយថ្ងៃចេញ មិនអាចទ្រាំបានប្រឈមមុខនឹងចៅក្រមបារាំងនោះទេ ជាចៅក្រមលាយឡំទៅដោយភាពលម្អៀង អសមត្ថភាព និងល្ងើ។ គេមិនយល់ថាលំបាកយ៉ាងណានោះទេ"។
- នៅក្នុងចម្លើយតបទៅនឹងសំណួរថាតើនឹងមានផលបំបាក់ដែរឬអត់ដោយសារការប្រព្រឹត្តិខុសរបស់ចុងចម្លើយនោះ ចុងចម្លើយបានឆ្លើយថា "ពិតណាស់ ខ្ញុំមិនច្បាស់ទេ។ សហមេធាវីមុនរបស់ខ្ញុំ គឺ Michiel [Pestman] និង Andy Ianuzzi ទទួលរងការប្ដឹងនៅគណៈមេធាវីអាំស្ទែដាំ និងញូយ៉ករៀងខ្លួន។ ខ្ញុំមិនគិតថា គណៈមេធាវីទាំងនោះបានឆ្លើយតបទេ។ តាមពិត ដូចដែលខ្ញុំបាននិយាយប្រាប់[សារព័ត៌មាន]ហើយ ខ្ញុំពិតជាសប្បាយចិត្តជាមួយនឹងរឿងនេះដែរ"។


Note: This Khmer translation is based on the English version which was translated from the original Dutch text.

នៅក្នុងសេចក្តីបន្ថែមទី ២ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៧ (ឧបសម្ព័ន្ធ ១៦) អ.វ.ត.ក បានដាក់បណ្តឹងទី ៣ ត្រង់បញ្ហាដែលថា ចុងចម្លើយ មិនបានគោរពតាមការហាមឃាត់អំពីគោលការណ៍រក្សាការសម្ងាត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដែលគាត់បានតាងនាមឱ្យកូនក្តីរបស់គាត់។ ចុងចម្លើយ បានស្នើសុំឱ្យលុបចោលការហាមឃាត់បែបនេះ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានគាំទ្រការហាមឃាត់នេះ ហើយបានជូនដំណឹងវិញថា សំណើសុំឱ្យពិចារណាឡើងវិញគួរដាក់ជូនអង្គជំនុំជម្រះ។ បន្ទាប់មក ចុងចម្លើយ បានផ្តល់ទឡ្ហីករណ៍ដូចខាងក្រោម៖ "ខ្ញុំយល់ឃើញថាមិនមានការជាប់ពាក់ព័ន្ធទាល់តែសោះចំពោះបញ្ហាថាតើ លោកចៅក្រមយល់ថាសមស្របដែរឬអត់ដែលខ្ញុំធ្វើអន្តរាគមន៍ដោយផ្ទាល់ជាមួយលោកចៅក្រមនោះ។ ឥឡូវនេះ លោកចៅក្រមគឺជាអ្នកដែលកំពុងរារាំងកូនក្តីខ្ញុំមិនឱ្យនិយាយដោយសេរី"។ រឿងបែបនេះមិនអាចទទួលយកបានទេ ដូចដែលខ្ញុំបានសរសេរជូនលោកចៅក្រម កាលពីម្សិលមិញរួចហើយ។ ខ្ញុំ មិន [...] យល់ឃើញថា ខ្ញុំត្រូវជាប់កាតព្វកិច្ចតាមអ្វីដែលលោកចៅក្រម ឬអង្គជំនុំជម្រះ ត្រូវនិយាយអំពីបញ្ហារក្សាការសម្ងាត់ទៀតទេ ហេតុនេះ ត្រូវបំពេញកិច្ចតាមហ្នឹង។ ភ្លាមៗបន្ទាប់ពីនោះមក អត្ថបទមួយឃើញមាននៅក្នុងសារព័ត៌មានឌី ខែមបូឌាដេលី ដោយមានការពិភាក្សាយ៉ាងច្រើនអំពីសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សារបស់ចុងចម្លើយ ហើយមានការបញ្ជាក់ថា សារព័ត៌មាននេះមានសំណៅមួយច្បាប់នៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សានេះ។

អ.វ.ត.ក នៅតែចាត់ទុកថា ទង្វើដែលបានប្តឹងតវ៉ានេះគឺជាការប្រព្រឹត្តខុសពីសំណាក់ចុងចម្លើយ ហើយនោះមានន័យថា អ.វ.ត.ក យល់ឃើញថា ចុងចម្លើយ បានរំលោភលើមាត្រា ៤៦ នៃលក្ខន្តិកៈមេធាវីដែលអនុវត្តចំពោះការវាយតម្លៃលើទង្វើដែលបានប្តឹងតវ៉ានេះ ហើយបើតាម អ.វ.ត.ក ចុងចម្លើយ បានប្រព្រឹត្តទង្វើក្នុងរបៀបមិនសមជាមេធាវី ដែលទទួលបានតួនាទីនេះឡើយ។

**៤. <u>ចុងចម្លើយ</u>** (ឧបសម្ព័ន្ធ ៤, ១២, ១៦ និង ២០)

ចុងចម្លើយ មិនបានជំទាស់ចំពោះអង្គហេតុដែលថា គាត់បានធ្វើសេចក្តីថ្លែងការណ៍នានាដែល អ.វ.ត.ក បានចោទគាត់ និងបានប្រព្រឹត្តទង្វើដែលដើមបណ្តឹងបានចោទគាត់ទេ។ ដោយពិនិត្យមើលកាលៈទេសៈដែលបានបង្ហាញនៅក្នុងសារណារបស់ចុងចម្លើយ ចុងចម្លើយបានបង្ហាញថា គាត់បានធ្វើសេចក្តីថ្លែងការណ៍រិះគន់យ៉ាងខ្លាំងលើចំណុចមួយចំនួនពាក់ព័ន្ធនឹងចៅក្រមមួយចំនួនក្នុងតួនាទីជាសមាជិកចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង (ខាងអន្តរជាតិ) ប៉ុន្តែ សេចក្តីថ្លែងការណ៍ទាំងនេះគឺផ្អែកទាំងស្រុងលើមុខងាររបស់ពួកគាត់ជាចៅក្រម មិនមែនលើបុគ្គលទេ ហេតុនេះ គាត់នៅតែស្ថិតនៅក្នុងដែនសេរីភាពដែលគាត់ទទួលបានក្នុងនាមជាអ្នកតំណាងឱ្យប្រយោជន៍របស់កូនក្តី។ ចុងចម្លើយ សន្និដ្ឋានថា ធាតុផ្សំផ្សេងៗនៃបណ្តឹងមិនមានមូលដ្ឋានឡើយ។


Note: This Khmer translation is based on the English version which was translated from the original Dutch text.

**៥. <u>ការស៊ើបអង្កេត</u> (ត)**

៥.១. ខ្ញុំបានបិទការស៊ើបអង្កេត ហើយបានរៀបចំឯកសារដាក់ក្នុងបញ្ជីឈ្មោះឯកសារ។ បញ្ជីឈ្មោះឯកសារនេះមានភ្ជាប់ជូន។

នៅថ្ងៃនេះ ខ្ញុំនឹងផ្ញើសំណៅមួយច្បាប់នៃលិខិតនេះ និងបញ្ជីឈ្មោះឯកសារនេះជូន អ.វ.ត.ក និងចុងចម្លើយ។

សូមលោកស្រី ទទួលនូវការគោរពអាប់អានដោយស្មោះអំពីខ្ញុំ។

[ហត្ថលេខា]
P.N van Regteren Atena

**បញ្ជីឈ្មោះឯកសារ- 40-15-0852**

អ.វ.ត.ក/លោក Koppe


Note: This Khmer translation is based on the English version which was translated from the original Dutch text.

| | | |
|---|---|---|
| ១ | លិខិតពីដើមបណ្តឹង ផ្ញើជូនប្រធានគណៈមេធាវី ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ ខែ ឆ្នាំ | បណ្តឹងទី ១ |
| ២ | អ៊ីមែលពីប្រធានគណៈមេធាវី ផ្ញើជូនចុងចម្លើយ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ | ការបញ្ជូនបណ្តឹង |
| ៣ | លិខិតពីប្រធានគណៈមេធាវី ផ្ញើជូនភាគីទាំងអស់ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ | ការពន្យល់អំពីនីតិវិធីបណ្តឹង និងសំណើសុំចម្លើយតប |
| ៤ | លិខិតពីចុងចម្លើយ ផ្ញើជូនប្រធានគណៈមេធាវី ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ | ចម្លើយតបទី ១ ទៅនឹងបណ្តឹង |
| ៥ | លិខិតពីប្រធានគណៈមេធាវី ផ្ញើជូនភាគីទាំងអស់ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៦ | សំណើសុំចម្លើយតបពីដើមបណ្តឹង ទៅនឹងចម្លើយតបទី ១ របស់ចុងចម្លើយ |
| ៦ | លិខិតពីដើមបណ្តឹង ផ្ញើជូនប្រធានគណៈមេធាវី ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦ | ចម្លើយតបពីដើមបណ្តឹង ទៅនឹងចម្លើយតបទី ១ របស់ចុងចម្លើយ |
| ៧ | លិខិតពីប្រធានគណៈមេធាវី ផ្ញើជូនដើមបណ្តឹង ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ | សំណើសុំផ្ញើសេចក្តីបន្ថែមលើបណ្តឹង |
| ៨ | លិខិតពីប្រធានគណៈមេធាវី ផ្ញើជូនចុងចម្លើយ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ | ការបញ្ជូនចម្លើយតបទៅនឹងបណ្តឹង និងការពន្យល់អំពីការវិវត្តនីតិវិធី |
| ៩ | លិខិតពីប្រធានគណៈមេធាវី ផ្ញើជូនដើមបណ្តឹង ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ | រំឭកអំពីសំណើសុំឲ្យបញ្ជូនសេចក្តីបន្ថែម |
| ១០ | លិខិតពីដើមបណ្តឹង ផ្ញើជូនប្រធានគណៈមេធាវី ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦ | ចម្លើយតបរបស់ដើមបណ្តឹង ដោយមានសេចក្តីបន្ថែមលើបណ្តឹង |
| ១១ | លិខិតពីប្រធានគណៈមេធាវី ផ្ញើជូនភាគីទាំង ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ | ការបញ្ជូនសេចក្តីបន្ថែមជូនទៅ ចុងចម្លើយ និងសំណើសុំចម្លើយតប |
| ១២ | លិខិតពីចុងចម្លើយ ផ្ញើជូនប្រធានគណៈមេធាវី ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៧ | ចម្លើយតបរបស់ចុងចម្លើយទៅនឹងសេចក្តីបន្ថែម |
| ១៣ | លិខិតពីប្រធានគណៈមេធាវី ផ្ញើជូនភាគីទាំងអស់ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៧ | ការបញ្ជាក់អំពីការទទួលបានឯកសារទាំងអស់ និងឱកាសដាក់ចម្លើយតបចុងក្រោយ និងការពន្យល់អំពីប្រាក់ប្រដាប់ក្តី |



Note: This Khmer translation is based on the English version which was translated from the original Dutch text.

| | | |
|---|---|---|
| ១៤ | លិខិតពីដើមបណ្តឹង ផ្ញើជូនប្រធានគណៈមេធាវី ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧ | ចម្លើយតបរបស់ដើមបណ្តឹងទៅនឹងចម្លើយតបទី ២ របស់ចុងចម្លើយ |
| ១៥ | លិខិតពីប្រធានគណៈមេធាវី ផ្ញើជូនភាគីទាំងអស់ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៧ | ការបញ្ជូនចម្លើយតបរបស់ដើមបណ្តឹង ជូនទៅចុងចម្លើយ និងសំណើសុំចម្លើយតប |
| ១៦ | លិខិតពីចុងចម្លើយ ផ្ញើជូនប្រធានគណៈមេធាវី ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៧ | ចម្លើយតបទី ៣ របស់ចុងចម្លើយ។ លះបង់សិទ្ធិមិនឆ្លើយតបអង្គសេចក្តីថែមទៀតទេ |
| ១៧ | អ៊ីមែលពីប្រធានគណៈមេធាវី ផ្ញើជូនភាគីទាំងអស់ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៧ | ការបញ្ជាក់អំពីការទទួលបានចម្លើយតបចុងក្រោយ ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត និងសំណើសុំវេរប្រាក់ប្រដាប់ក្តី |
| ១៨ | លិខិតពីដើមបណ្តឹង ផ្ញើជូនប្រធានគណៈមេធាវី ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៧ | ព័ត៌មានថ្មីពីដើមបណ្តឹង សេចក្តីបន្ថែមទី ២ |
| ១៩ | អ៊ីមែលពីប្រធានគណៈមេធាវី ផ្ញើជូនភាគីទាំងអស់ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៧ | ការបញ្ជូនសេចក្តីបន្ថែមទី ២ ជូនទៅចុងចម្លើយ និងសំណើសុំចម្លើយតប |
| ២០ | អ៊ីមែលពីចុងចម្លើយ ផ្ញើជូនប្រធានគណៈមេធាវី ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ | ចម្លើយតបរបស់ចុងចម្លើយទៅនឹងសេចក្តីបន្ថែមទី ២។ លះបង់សិទ្ធិមិនឆ្លើយតបអង្គសេចក្តីថែមទៀតទេ |



Note: This Khmer translation is based on the English version which was translated from the original Dutch text.